ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

កសវ



## Work Activities

ប្រចាំខែ មីនា ឆ្នាំ ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ប្រាក់ម៉ោងយាមប្រចាំការជូនមន្ត្រីរាជការ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព | ១ |
| ២- | សេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍយុវជនកម្ពុជា | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសានិងអក្សរខ្មែរលើរូបសញ្ញា | ៤ |
| ៤- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម | ៥ |
| ៥- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន | ៦ |
| ៦- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឃោធិនជាប់កិច្ចសន្យា | ៧ |
| ៧- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១ | ៨ |
| ៨- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការផ្តល់ប្រាក់ម៉ោងយាមប្រចាំការជូនមន្ត្រីរាជការ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព



កាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម សំអាត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ប្រាក់ម៉ោងយាមប្រចាំការជូនមន្ត្រីរាជការនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសុខាភិបាល សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

កន្លងមកក្រសួងសុខាភិបាលបានអនុវត្តប្រាក់យាមប្រចាំការនេះ តាមអនុក្រឹត្យលេខ២០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពី ការកែលំអរបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ តែការអនុវត្តតាមទម្រង់ប្រាក់ម៉ោងយាមនេះ មិនទាន់បានសុក្រឹត្យនៅឡើយ នាំឱ្យមានលេចចេញនូវបាតុភាពជាច្រើន ម៉្យាងដោយមានការប្រែប្រួលថវិកាខ្លាំងក្នុងការអនុវត្តន៍ប្រាក់ឧបត្ថម្ភយាមប្រចាំការ និងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនមានមូលដ្ឋានផ្តល់ថវិកាតាមអនុក្រឹត្យចាស់ផង ទើបក្រសួងសុខាភិបាល ស្នើសុំឲ្យមានការពិភាក្សាឡើងវិញ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយជាលទ្ធផលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពទៅលើខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យថ្មីនេះ តាមរយៈលិខិតជូនដំណឹងលេខ ៦៣៤៩ សហវ-ថ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១០។

សេចក្តីព្រាងអនុក្រឹត្យស្តីពី ការផ្តល់ប្រាក់ម៉ោងយាមប្រចាំការជូនមន្ត្រីរាជការ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព តាក់តែងឡើងក្នុងគោលបំណងសំខាន់ៗជាអាទិ៍៖

-ផ្តល់ប្រាក់របបម៉ោងយាមដល់មន្ត្រីក្របខណ្ឌសុខាភិបាល

-ចំពោះមន្ត្រីក្របខណ្ឌសុខាភិបាលជាន់ខ្ពស់ ឧបត្ថម្ភ ២០ ០០០រៀល ក្នុង១វេន ២៤ម៉ោង

-មន្ត្រីក្របខណ្ឌសុខាភិបាលបឋមនិងមធ្យម ឧបត្ថម្ភ ១៥ ០០០ រៀល ក្នុង១វេន ២៤ម៉ោង

-ចំពោះមន្ត្រីគ្រប់គ្រងរដ្ឋបាល ឧបត្ថម្ភ ១០ ០០០រៀល ក្នុង១វេន២៤ម៉ោង

ប្រាក់របបម៉ោងយាមនេះ មិនត្រូវបានផ្តល់ជូនមន្ទីរពេទ្យជាតិ ឬអង្គភាពទាំងឡាយ ដែលមានលក្ខណៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាលទេ(១)។







អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើ សេចក្តីព្រាងឯកសារនេះទាំងស្រុង ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ប្រាក់ម៉ោងយាមប្រចាំការជូនមន្ត្រីរាជការនៅតាម មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក ។

## សេចក្តីព្រាងគោលនយោបាយស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា



កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **នូ ទេពីរិទ្ធ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍយុវជនកម្ពុជា** ដោយមានការអញ្ជើញចូលរួមប្រជុំពីសំណាក់ តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

អនុវត្តតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំ ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំច្បាប់ស្តីពីការអប់រំ។ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងបានរៀបចំផែនការកសាងលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព ដែលក្នុងនោះក៏មានគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាផងដែរ។ យុវជនក្នុងគោលនយោបាយនេះសំដៅដល់មនុស្សវ័យចាប់ ពីអាយុ១៥ ដល់៣០ឆ្នាំ។

ការរៀបចំគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា មានគោលបំណងឱ្យយុវជនទទួលបាននូវឱកាសនៃការអប់រំ ការលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ និងការចូលរួមប្រកបដោយសមធម៌នៅក្នុងសង្គម។ គោលនយោបាយនេះក៏បានកំណត់ផងដែរអំពីការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការងារ ពិសេសច្បាប់ស្តីពីការអប់រំ ត្រង់មាត្រា១៧ ចែងថា " ការអប់រំចំណេះទូទៅជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ និងធានាឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន។ " និងមាត្រា១៨ វាក្យខណ្ឌទី២ ចែងថា " ការអប់រំឧត្តមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឱ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើត និងស្មារតីសហគ្រិនភាព សម្រាប់អភិវឌ្ឍប្រទេសជាតិ " (១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ដែលជារួមខ្លឹមសារមានអត្ថន័យសមស្របច្រើនហើយ។ ក្រោយពីបានពិភាក្សារួចមក អង្គប្រជុំបានសម្រេចឱ្យក្រសួងសាមីកែសម្រួលនូវចំណុចមួយចំនួនដែលអង្គប្រជុំយល់ឃើញថាមានសារៈសំខាន់ដូចជាទម្រង់ដែលត្រូវរៀបចំឡើងវិញតាមគំរូថ្មី និងខ្លឹមសារខ្លះៗបន្ថែមទៀត ដើម្បីយកមកដាក់ប្រជុំជំនាញបច្ចេកទេសនៅពេលក្រោយទៀត។ អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការប្រើប្រាស់ភាសានិងអក្សរខ្មែរលើរូបសញ្ញា



កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **កែប ចិច្ចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសានិងអក្សរខ្មែរលើរូបសញ្ញា** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងគណៈកម្មាធិការជាតិភាសាខ្មែរ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឮកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសានិងអក្សរខ្មែរលើរូបសញ្ញា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០។ អង្គប្រជុំនៅពេលនោះ បានសម្រេចឱ្យស្ថាប័នសាមីយកសេចក្តីព្រាងនេះទៅកែសម្រួលឡើងវិញសម្រាប់ការប្រជុំលើកក្រោយ ដោយបង្រួមសមត្ថកិច្ចមកនៅត្រឹមការត្រួតពិនិត្យការប្រើប្រាស់ភាសានិងអក្សរលើសញ្ញា។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងកែសម្រួលថ្មីនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារពាក្យពេចន៍ ឃ្លាប្រយោគបន្ថែមទៀតដើម្បីឱ្យសេចក្តីព្រាងនេះកាន់តែល្អ៕





## កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី

# ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម



កាលពីថ្ងៃទី១ ទី៣ ទី១០ ទី១៦ ទី២២ និងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:00នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម សំអាត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាបន្តលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕





## កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបញ្ជូនពលករខ្មែរទៅធ្វើការ នៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន

កាលពីថ្ងៃទី២៣ និងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ភូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយភ្នាក់ងារជ្រើសរើសឯកជន បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១។ អង្គប្រជុំនៅពេលនោះបានសម្រេចបង្កើតក្រុមការងារបង្អៀតដើម្បីជួយរៀបចំឡើងវិញចាប់ពីជំពូកទី២ ដែលនិយាយអំពីស្ថាប័នមានសមត្ថកិច្ចជាភារកិច្ចរបស់ក្រសួង និងខ្លឹមសារដែលនិយាយអំពីទីភ្នាក់ងារជ្រើសរើសវិញ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងថ្មីនេះចាប់ពីជំពូកទី១ ឡើងវិញ ពិសេសយកចិត្តទុកដាក់ខ្លាំងដល់ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរ ដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចនានា ដែលត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់៕





## កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# យោធិនជាប់កិច្ចសន្យា

កាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **កែវ ទិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីយោធិនជាប់កិច្ចសន្យា** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងការពារជាតិ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យ និងពិភាក្សាបន្តចាប់ពីមាត្រា៨ នៃសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើ សេចក្តីព្រាងឯកសារនេះទាំងស្រុង ៕





# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១១



កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែកុម្ភៈ ឆ្នាំ២០១១** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ ក្នុងខែកុម្ភៈ ឆ្នាំ២០១១ នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ **កើនឡើង ០៧.%** បើធៀបនឹងខែមុន និង**កើនឡើង ៣.៨%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ ការកើនឡើងនៃសន្ទស្សន៍ថ្លៃខែ **កុម្ភៈ|មករា** មានការរួមចំណែក នៃក្រុមម្ហូបអាហារ ៤១% ក្រុមផ្ទះ សំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត ១៩% ការដឹកជញ្ជូន ១៦% និងភោជនីយដ្ឋាន ១៩%។

➡ បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ (កុម្ភៈ/មករា) បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល ១២ខែ) | | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ▪ ម្ហូបអាហារៈ +0.៧% | ( +៤% ) | ▪ សំលៀកបំពាក់ និងស្បែកជើងៈ –១.២% | ( +0.៣% ) |
| ▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ +0.៨% | ( +៣.៣% ) | ▪ គ្រឿងសង្ហារឹម និងសំភារៈប្រើប្រាស់ៈ–0.៣% | ( +0.៦% ) |
| ▪ សុខាភិបាលៈ +0.២% | (+១%) | ▪ ទូរគមនាគមន៍ៈ –0.៤% | ( +២% ) |
| ▪ ការដឹកជញ្ជូនៈ +0.៩% | ( +៥.៥% ) | ▪ ការកំសាន្ត និងវប្បធម៌ៈ –0.៥% | ( 0% ) |
| ▪ ភោជនីយដ្ឋានៈ +២.២% | ( +៧% ) | | |
| ▪ ទំនិញ និងសេវាកម្មផ្សេងទៀតៈ +១.២% | ( +៧.៩% ) | | |

➡ តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងអំលុង ៣ឆ្នាំចុងក្រោយ។

| ឆ្នាំ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ ធៀបនឹង... | ខែដូចគ្នាឆ្នាំមុន | ៣.៣% | ៣.៨% | | | | | | | | | | | |
| | ខែមុន | 0.២% | 0.៧% | | | | | | | | | | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦.៩% | ៧.៣% | ៦.៧% | ៥.៣% | ៤.៥% | ២.៥% | ១.៦% | ១.៧% | ១.៩% | ៣.៦% | ៣.២% | ៧.៣% | ៤% |
| | ខែមុន | 0% | 0.៣% | 0.៦% | -0.៣% | 0.២% | 0% | 0.៥% | 0.៩% | 0.៧% | ១.៤% | –១.0% | –0.២% | |
| ២00៩ | ខែដូចគ្នាឆ្នាំមុន | ៨.0% | ៦.២% | -0.៧% | -៣.៩% | -៥.៧% | -៤.៨% | -៣.៩% | -២.៩% | -២.៣% | -១.៥% | ១.៣% | ៨.0% | -0.៧% |
| | ខែមុន | -១.៥% | -0.១% | ១.៣% | ១.0% | ១.0% | ១.៩% | ១.៤% | 0.៧% | 0.៥% | -0.៣% | -0.៦% | -0.១% | |

➡ រូបនៅខាងស្តាំដៃ បង្ហាញថាបម្រែបម្រួលសន្ទស្សន៍ថ្លៃ ធៀបនឹងខែដូចគ្នា (**Month on month**) មានកំរិតខ្ពស់នៅដើមឆ្នាំ បន្ទាប់មកថយចុះ និងឡើងខ្ពស់វិញនៅចុងឆ្នាំ។




➡ ជារួមប្រាក់រៀលមានស្ថេរភាពធៀបនឹងរូបិយវត្ថុបរទេស។ ក្នុងខែនេះ អត្រាប្តូរប្រាក់ **៛/ដុល្លារ** ស្មើនឹង **៤,០៣៦៛/១ដុល្លារ** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ០.៣% ធៀបនឹងដុល្លារ និងឡើងថ្លៃ ៣.៥% ក្នុងរយៈពេល ១២ខែ ។

➡ អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣២៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក ១.៥% ធៀបនឹងបាត និងចុះថោក ៤.៨% ក្នុងរយៈពេល ១២ខែ។

➡ អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **០.១៩៣៛/១ដុង** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ៧.២% និងឡើងថ្លៃ ១៣.១% ធៀបនឹងដុង ក្នុងរយៈពេល ១២ខែ។

➡ យោងតាមអត្រាប្តូរប្រាក់ **ដុង/ដុល្លារ** និង**បាត/ដុល្លារ** យើងសង្កេតឃើញថា តម្លៃប្រាក់ដុងមាននិន្នាការចុះថោក ធៀបនឹងដុល្លារ ឯប្រាក់បាតមាននិន្នាការឡើងថ្លៃ ធៀបនឹងដុល្លារ។

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ **នាខែកុម្ភៈ ឆ្នាំ២០១១ នេះ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳***ចំណូល អនុវត្តបានចំនួន ៥១៩ ពាន់លានរៀល*** *(ជាមធ្យមប្រចាំខែស្មើនឹង ៧៩% នៃគម្រោង) ក្នុងនោះ* ***ចំណូលមូលធន ៩៣.៧ ពាន់លានរៀល*** *(ជាមធ្យម ១៤៥% នៃគម្រោង) និង****ចំណូលចរន្ត ៤២៥.៤ ពាន់លានរៀល*** *(ជាមធ្យម ៧៥% នៃគម្រោង)* ។

↳ បើធៀបនឹងខែមុន**ចំណូល**កើនឡើង ៣២% និង**កើនឡើង ១២%** ក្នុងរយៈពេល ១២ខែ។ ការកើនឡើងក្នុងខែនេះ គឺបណ្តាលមកពីចំណូលមូលធន កើនឡើងយ៉ាងគំហុក និងចំណូលចរន្តកើនឡើង ៩%។

↳ប្រភពចំណូលមូលធននាខែនេះគឺ ការបង់ប្រាក់របស់ធនាគារអភិវឌ្ឍន៍ជនបទ លើការប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម រួមនឹងការឧបត្ថម្ភធនពីធនាគារអភិវឌ្ឍន៍អាស៊ី និងគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានរបស់ធនាគារពិភពលោក។

↳ គួរចាប់អារម្មណ៍ថា ចំណូលចរន្តថយចុះ ៧.៦% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ ក្នុងចំណូលចរន្ត:

- ✓ ចំណូលសារពើពន្ធកើនឡើង ១% និងកើនឡើងតែ ០.៣% ប៉ុណ្ណោះ ក្នុងរយៈពេល ១២ខែ
- ✓ ចំណូលមិនមែនសារពើពន្ធកើនឡើង៧៤% ប៉ុន្តែថយចុះ ៣៣% ក្នុងរយៈពេល ១២ខែ

| **ក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ✓ ពន្ធ និងអាករគយ: -៦% | (+៨.១%) | ✓ នេសាទ: -៣៦% | (-៥១%) |
| ✓ ចំណូលពន្ធដារ: -៨.៧% | (+១៣%) | ✓ រុក្ខាប្រមាញ់: +៣០៨% | (+៣៩៤%) |
| ✓ ចំណូលសារពើពន្ធផ្សេងៗ: +១៤០% | (+៨៧%) | ✓សម្បទានរ៉ែ: +១៤០% | (+៣២៦%) |
| | | ✓ អាកាសចរណ៍ស៊ីវិល: +៩១៤% | (+១៧%) |
| | | ✓ ផលទុនទេសចរណ៍: កើនគំហុក | (កើនគំហុក) |
| | | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍: -៥០% | (-៤៧%) |
| | | ✓ ឯកជនភាវូបនីយកម្ម: -៩៨% | (-១០០%) |
| | | ✓ ការលក់អចលនកម្ម: +៤៦០% | (កើនគំហុក) |

- ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៤២០ពាន់លានរៀល ក្នុងនោះ **ចំណាយចរន្ត** ៣៧៦ពាន់លានរៀល និង**ចំណាយមូលធន** ៤៤ ពាន់លានរៀល។

- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ**កើនឡើង ៣១៨% និងកើនឡើង ១៧% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្តកើនឡើង ៣១៨% (រយៈពេល ១២ខែ: +១៧%) និងចំណាយមូលធន*កើនឡើង ២១៤%* (រយៈពេល ១២ខែ: -២២%) ។

- ***តុល្យភាពថវិកាជាតិក្នុងខែកុម្ភៈនេះមានអតិរេកចំនួន ៩៩ ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុ និងអត្រាការប្រាក់

➡ ក្នុងខែកុម្ភៈ ឆ្នាំ២០១១ ស្ថានភាពរូបិយវត្ថុមានលក្ខណៈដូចខាងក្រោម៖

- **រូបិយវត្ថុ** $M_2$ មានចំនួន ***១៩,៨៧០ ពាន់លានរៀល*** កើនឡើង ១% ធៀបនឹងខែមុន (និងកើនឡើង ១៧% ក្នុងរយៈពេល ១២ខែ។ កំណើននៃ M2 នេះបណ្តាលមកពីរូបិយវត្ថុ M1 កើនឡើង ៤.១% (រយៈពេល ១២ខែ: +៧.៣%) និងរូបិយវត្ថុផ្សេងៗកើនឡើង 0.៣% (រយៈពេល ១២ខែ: +១៩%)។

| | | |
|---|---|---|
| **M2 = M1 + Quasi-money** +១% (+១៧%) | **$M_1$** +៤.១% (+៧.៣%) | ✓ រូបិយវត្ថុក្រៅធនាគារកើនឡើង ៣.៣% (រយៈពេល ១២ខែ: +៦.៥%)<br>✓ ប្រាក់បញ្ញើចរន្តកើនឡើង ២១.៣% (រយៈពេល ១២ខែ: +២៧%) |
| | រូបិយវត្ថុផ្សេងៗ (Quasi-money) +0.៣% (+១៩%) | ✓ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំកើនឡើង១៣% (រយៈពេល ១២ខែ: +២៩%)<br>✓ ប្រាក់បញ្ញើជារូបិយបណ្ណនៅដដែល (រយៈពេល ១២ខែ: +១៨%) |

- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២,៦៥៨ លានដុល្លារ** *កើនឡើង ៣.៤%* ធៀបនឹងខែមុន និងកើនឡើង ១៤.៦% ក្នុងរយៈពេល ១២ខែ។
- *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* មានចំនួន **៧,១២៩ ពាន់លានរៀល** កើនឡើង 0.៨% បើធៀបនឹងខែមុន និងកើនឡើង ១៤% ក្នុងរយៈពេល ១២ខែ។
- *ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ* ជារួមមានការកើនឡើង ដោយឡែកក្នុងខែកុម្ភៈនេះមានចំនួន ៣,៦២៥ ពាន់លានរៀល កើនឡើង ១.៤% បើធៀបនឹងខែមុន និងកើនឡើង ២៤% ក្នុងរយៈពេល ១២ខែ។
- *ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ* មានចំនួន **១,៨៧៨ ពាន់លានរៀល** កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ៤៧% ក្នុងរយៈពេល ១២ខែ។
- *អត្រាការប្រាក់ប្រចាំឆ្នាំ៖*

| (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល១២ ខែ) | | | |
|---|---|---|---|
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ: -0.៥% | ( -១៤% ) | ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ: -0.៥% | ( ៤.៨%) |
| ▪ កំចីជាដុល្លារនៅធនាគារពាណិជ្ជ: -0.២% | ( -១.៨% ) | ▪ កំចីជារៀលនៅធនាគារពាណិជ្ជ: -0.២% | ( -២.៥%) |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងខែកុម្ភៈ ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➡ កសិកម្ម៖

✓ ផលិតកម្មនេសាទ: ពីរខែដើមឆ្នាំ ២០១១ នេះ មិនមានតួលេខ។

➡ ឧស្សាហកម្ម៖

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៦៤.៥ លានដុល្លារ (បានពី ២០៧ រោងចក្រ) ថយចុះ ១.៦% ប៉ុន្តែកើនឡើង ២០% ក្នុងរយៈពេល ១២ខែ។

✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៩៣.៨ លានគីឡូវ៉ាត់ម៉ោង ថយចុះ ០.៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៧% ក្នុងរយៈពេល ១២ខែ។

– អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ១.៥ លានគីឡូវ៉ាត់ម៉ោង ថយចុះ ៦៥% បើធៀបនឹង ខែមុន ប៉ុន្តែកើនឡើង ១៤៤.៣% ក្នុងរយៈពេល ១២ខែ។

✓ រោងចក្រ សហគ្រាសៈក្នុងខែកុម្ភៈ

| ប្រភេទ | ចំនួនក្នុងខែកុម្ភៈ |
|---|---|
| ▪ ចំនួនរោងចក្រថ្មី ដែលបានចុះបញ្ជី | ១០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១២ |

➡ សំណង់៖

**សំណង់អនុញ្ញាតឲ្យសាងសង់** មានចំនួន ២៧២.៧ ពាន់ម$^2$ ថយចុះ ២៧% បើធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ១២៧% ក្នុងរយៈពេល ១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ៨៥.៣ លានដុល្លារ ថយចុះ ២៤% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨៨% ក្នុងរយៈពេល ១២ខែ។

**សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (៥០% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) ទេសចរណ៍ (២៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងឧស្សាហកម្ម (១៦% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

➡ វិនិយោគ៖ នាខែនេះគម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) មានចំនួន **៧**។ បើគិតជាទុនវិនិយោគស្មើនឹង **១០៥ លានដុល្លារ** ថយចុះ ២៦.៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣០% ក្នុងរយៈពេល ១២ខែ ក្នុងនោះ ៧៧ លានដុល្លារ (៧៣%) ហូរទៅវិស័យទេសចរណ៍ និង ២៣ លានដុល្លារ (២២%) ហូរទៅវិស័យឧស្សាហកម្ម។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន ៦ ពាន់នាក់។

➡ សេវាកម្ម និងទេសចរណ៍៖

**ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្មក្នុងខែកុម្ភៈនេះមានចំនួន **២៣០**។

**ក្រុមហ៊ុនដែលបានចុះបង់ពន្ធដារតាមរបបពិត** ក្នុងខែកុម្ភៈនេះដែរ មានចំនួន **២៤៦**។

**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប៦ កំពង់ផែ) មានចំនួន ៣២០.៨ ពាន់តោន កើនឡើង ១% ធៀបនឹងខែមុន និង កើនឡើង ៤% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| (ក្នុងវង់ក្រចកៈ បម្រែបម្រួលក្នុងរយៈពេល ១២ខែ) | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ -២៨ | ( -៦% ) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ +៩៣៥% | ( -៥២% ) |
| ▪ កំពង់ផែកំពង់សោមៈ +៥.៤% | ( +៣០% ) | ▪ កំពង់ផែស្រែអំបិល និងកំពង់ផែកោះកុងៈ +១៦៥% | ( +៥៨% ) |

**អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ២៥២ ពាន់នាក់ ថយចុះ ៨% បើធៀបនឹងខែមុន និងថយចុះ ៩% ក្នុងរយៈពេល ១២ខែ។

ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិមានចំនួន ១៣,៤០៣ នាក់ កើនឡើង ៦៣% បើធៀបនឹងខែមុន និងកើនឡើង ២០% ក្នុងរយៈពេល ១២ខែ។




**ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស**មាន ៤២ ពាន់ នាក់ ថយចុះ ១២% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៨% ក្នុងរយៈពេល ១២ខែ។

**ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា** ជាទូទៅ មានចំនួនច្រើននៅដើមឆ្នាំ និងចុងឆ្នាំ។ ក្នុងខែនេះ មានចំនួន ២៥៥ ពាន់នាក់ ថយចុះ ៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ) | | | |
|---|---|---|---|
| ▪ តាមផ្លូវអាកាស: -៥% | ( +១៩% ) | ▪ តាមផ្លូវគោក និងទឹក: -៩.៦% | (+២៥% ) |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែកុម្ភៈ មានចំនួន ១,៦៨១ ពាន់លានរៀល ថយចុះ ១0% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ទំនិញដែលកើនឡើង (កុម្ភៈ/មករា) (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ) | | ទំនិញដែលថយចុះ (កុម្ភៈ/មករា) (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ) | |
|---|---|---|---|
| - ស៊ីម៉ង់: +២២% | ( +៦%) | - ប្រេងឥន្ធនៈ -៦% | ( +៨%) |
| - ត្រាក់ទ័រនិងគោយន្ត: +១៣% | ( +៣៦%) | - ឧស្ម័នៈ -២១% | ( -៥%) |
| - ម៉ូតូ: +៣១៣% | ( +៤១%) | - អគ្គិសនីនាំចូល: -១៧% | ( +0.៦%) |
| - ជីនិងថ្នាំកសិកម្ម: +២៣% | ( +៤៨%) | - ដែកសំណង់: -៤៤% | ( -៦%) |
| | | - គ្រឿងអេឡិចត្រូនិច: -៥៣% | ( -១៣%) |
| | | - រថយន្តសរុប (ពាន់លានរៀល): -១0% | ( +១១%) |
| | | - ផ្លែឈើនិងបន្លែ: –៤២% | ( –២៨%) |
| | | - នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ: –២៨% | ( +១0%) |

➡**ការនាំចេញ** ក្នុងខែកុម្ភៈ ឆ្នាំ២០១១ មានចំនួន ១,២៨៧ ពាន់លានរៀល ថយចុះ ១៣% ធៀបនឹងខែមុន ប៉ុន្តែកើន ឡើង ៣0% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះមុខទំនិញមួយចំនួនមាន៖

| (ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ) | | | |
|---|---|---|---|
| ▪ វាយនភណ្ឌនិងស្បែកជើង: -១៤% | ( +២១% ) | ▪ ផលិតផលឈើកែច្នៃ: +៥៤២% | (+៣២%) |
| ▪ កៅស៊ូ: -១៥% | ( +២៨៣% ) | ▪ អង្ករ: +១២% | (+២២៨%) |

➡ *ក្នុងខែកុម្ភៈ ឆ្នាំ២០១១ នេះជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៣៩៤ ពាន់លានរៀល។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) **អតិផរណា:** ការឡើងថ្លៃគួរឲ្យព្រួយបារម្ភនៃប្រេងសាំង និងម៉ាស៊ូត ជាកត្តាដែលធ្វើឲ្យមុខទំនិញផ្សេងទៀត មានការឡើងថ្លៃដែរ។

ក.ស.វ. ធ្លាប់បានបង្ហាញអំពីគំលាតថ្លៃប្រេងសាកលលោក ថ្លៃនាំចូល និងថ្លៃលក់រាយនៅព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំ ជាមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន ការឡើងថ្លៃខ្លាំងនៃទំនិញនេះ ពិតជាសម្ពាធមួយយ៉ាងធ្ងន់មកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

២) សេដ្ឋកិច្ចកម្ពុជាមានគំលាតធំ រវាងអត្រាការប្រាក់បញ្ញើ និងអត្រាការប្រាក់កំចី។ អត្រាការប្រាក់កំចីនាពេលបច្ចុប្បន្នមានកំរិតខ្ពស់ ដែលបង្ករការលំបាកដល់ការលូតលាស់សហគ្រាសធនតូច និងមធ្យម និងការអភិវឌ្ឍធុរកិច្ចជារួម។

***ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖***

*១) ការឡើងថ្លៃទំនិញជាសកល ជាពិសេសម្ហូបអាហារ អាចជាឱកាសសម្រាប់ប្រទេសកសិកម្ម ដូចជាកម្ពុជាក្នុងការទាញយកផលចំណេញពីស្ថានភាពនេះ។ ដូច្នេះកសិកម្មនៅតែជាវិស័យអាទិភាព ក្នុងការបង្កើតបរិយាកាសវិនិយោគ ការកៀងគរវិនិយោគ និងជំរុញការនាំចេញផលិតផលកសិកម្ម។*

*២) គោលនយោបាយរូបិយវត្ថុ មានដែនកំណត់ក្នុងការប្រើប្រាស់ឧបករណ៍រូបិយវត្ថុ (ដូចជា Discount Rate Policy និង Open Market Operations ) ដើម្បីជះឥទ្ធិពលជាវិជ្ជមានមកលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច។ អត្រាការប្រាក់នាពេលបច្ចុប្បន្នកំណត់ដោយទីផ្សាររវាងធនាគារពាណិជ្ជ និងអ្នកផ្ញើរ/អ្នកខ្ចី ។ ធនាគារជាតិនៃកម្ពុជា មិនទាន់មានអន្តរាគមដោយផ្ទាល់មកលើអត្រាការប្រាក់នៅឡើយ។*

## ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈ ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល ១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. ថ្លៃប្រេងសាំង (ម៉ាស៊ូត) | +២.៣% (+៣.៣%) | +១៦% (+២១%) | — |
| ២. បំណុលមូលធន | +៣២៧៨% | +៣៩៧៤% | -ធនាគារអភិវឌ្ឍន៍ជនបទ ទូទាត់លើការប្រើប្រាស់មូលនិធិអភិវឌ្ឍន៏វិស័យកសិកម្ម<br>-ការឧបត្ថម្ភធនពីធនាគារអភិវឌ្ឍន៍អាស៊ី<br>-ធនាគារពិភពលោកអនុវត្តគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន |
| ៣. បំណុលចរន្ត | +៩.១% | -៧.៦% | — |
| ៤. បំណុលពីរុក្ខាប្រមាញ់ (មិនមែនសារពើពន្ធ) | +៣០៨% | +៣៩៤% | — |
| ៥. ផលទុននៃសកម្មភាពទេសចរណ៍ | +៣៦១៩៥៥% | +២៤១៣៦០៣% | - **Sokha Hotel** ទូទាត់ **Royalty** ពីការបង្ហោះ **Ballon** នៅខេត្តសៀមរាប |
| ៦. លក់អចលនកម្ម | +៤៦០% | +៩០៨១៥០% | - លក់ **Midana Food Factory**<br>- លក់សណ្ឋាគារជ័យជំនះ |
| ៧. ការនាំចេញផលិតផលឈើកែឆ្នៃ | +៥៤២% | +៣២% | — |
| ៨.ការនាំចេញអង្ករ | +១២% | +២២៨% | — |

**កំណត់សម្គាល់៖**

-ព័ត៌មាន និងទិន្នន័យពណ៌ **បៃតង** សំដៅលទ្ធផលល្អប្រសើរ

-ព័ត៌មាន និងទិន្នន័យពណ៌ **ក្រហម** សំដៅលទ្ធផលសម្រាប់ការប្តឹងថ្លែង

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែមីនា ឆ្នាំ២០១១**

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៣/១១<br>ម៉ោង ១៥:៣០ នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើ៖<br>១-សេចក្តីព្រាង ផែនការយុទ្ធសាស្ត្រជាតិ ដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ នៅព្រះរាជាណាចក្រកម្ពុជា ២០១១-២០២៥ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនពិការ និងគ្រួសារក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៣/០៣/១១<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីបិទមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ឆ្នាំ២០១១ និងការប្រារព្ធទិវាវប្បធម៌ជាតិ លើកទី១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅសាលសន្និសីទចតុមុខ ។ |
| ៣ | ០៣/០៣/១១<br>ម៉ោង ១៥:០០ នាទី | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ឱម យិនទៀង** នៅរាជធានីភ្នំពេញ ។ |
| ៤ | ០៤/០៣/១១<br>ម៉ោង ១៩:០០ នាទី | ចូលរួមប្រជុំការសាងសង់គណៈកម្មាធិការបុរីរដ្ឋបាលសៀមរាប នៅរាជធានីភ្នំពេញ ។ |
| ៥ | ០៧/០៣/១១<br>ម៉ោង ០៩:០០ នាទី | ប្រជុំពិភាក្សាការងារជាមួយលោកជំទាវ **គាល់ ណៃអ៊ីម** សមាជិកាថ្មី នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ០៧/០៣/១១<br>ម៉ោង ១៤:៣០ នាទី" | ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរ ខួបលើកទី ១០០ ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "យុវវ័យជួយស្ត្រី គឺជួយខ្លួនឯង និងសង្គមជាតិ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ០៩/០៣/១១<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ចំណតកុងតឺន័រថ្មីរបស់កំពង់ផែស្វយ័តភ្នំពេញ ក្រោមឥណទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ |
| ៨ | ០៩/០៣/១១<br>ម៉ោង ១៦:០០ នាទី" | ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន សម្បទានព្រលានយន្តហោះ SCA នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៩ | ១០/០៣/១១<br>ម៉ោង ០៨:១៥នាទី | ចូលរួមប្រជុំការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |

| | | |
|---|---|---|
| ១០ | ១០/០៣/១១<br>ម៉ោង ១៩:៣០នាទី" | ចូលរួមប្រជុំត្រួតពិនិត្យការងារអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។" |
| ១១ | ១១/០៣/១១<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំការងារជាមួយ ឯកឧត្តម អគ្គលេខាធិការថ្មី និង អគ្គលេខាធិការរង នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១២ | ១៤/០៣/១១<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ ។ |
| ១៣ | ១៤/០៣/១១<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំការងារជាមួយ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៤ | ១៥/០៣/១១<br>ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ឆាត់ លេខ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៥ | ១៥/០៣/១១<br>ម៉ោង ១៤:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតសុខាភិបាលលើកទី៣២ និងការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ លើកទី៩ លើសមិទ្ធផលសុខាភិបាលឆ្នាំ២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ។ |
| ១៦ | ១៧/០៣/១១<br>ម៉ោង ០៩:០០នាទី | ចូលរួមចុះពិនិត្យការដ្ឋានសាងសង់ អគារមជ្ឈមណ្ឌលតំកល់ឯកសារច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការិយាល័យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ។ |
| ១៧ | ១៨/០៣/១១<br>ម៉ោង ០៨:៣០នាទី" | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១.សេចក្តីព្រាងយុទ្ធសាស្ត្រជាតិ ស្តីពីការគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ។<br>២.សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយ ចំពោះជនពិការ និងគ្រួសារក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ ។<br>៣.បញ្ហាផ្សេងៗ ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ "ពិធីសារទី៣ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍" ។ |
| ១៨ | ២២/០៣/១១<br>ម៉ោង ០៧:៣០នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០០៩-២០១០ និងលើកទិសដៅឆ្នាំសិក្សា ២០១០-២០១១ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ ។ |
| ១៩ | ២២/០៣/១១<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីប្រាក់ឧបត្ថម្ភម៉ោងយាមប្រចាំការ ជូនមន្ត្រីរាជការនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីសី[illegible] គណៈរដ[illegible] [illegible] |

| | | |
|---|---|---|
| ២០ | ២៣/០៣/១១ ម៉ោង៩:០០នាទី" | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ២១ | ២៣/០៣/១១ ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១០ និងទិសដៅអនុវត្តការ ងារឆ្នាំ២០១១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតី ភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទ ចតុមុខ ។ |
| ២២ | ២៤/០៣/១១ ម៉ោង០៩:០០នាទី | ប្រជុំពិភាក្សាការងារជាមួយលោក ALAIN BRUN អគ្គនាយកថ្មីនៃអាជ្ញាធរអប្សរា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៤/០៣/១១ ម៉ោង ១៤:០០ នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០០៩-២០១០ និងលើកទិសដៅឆ្នាំសិក្សា ២០១០-២០១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ ។ |
| ២៤ | ២៥/០៣/១១ ម៉ោង ៩:០០នាទី | ចូលរួមប្រជុំពិនិត្យការកែសម្រួលប្លង់ អគារមជ្ឈមណ្ឌលតំកល់ឯកសារច្បាប់នៃអង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការិយាល័យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | ២៨/០៣/១១ ម៉ោង០៩:០០នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារវិទ្យាស្ថានខុងជឺ សាលសន្និសីទ របង និងប្រព័ន្ធលូ និងពិធីប្រគល់សញ្ញាបត្រកិត្តិបណ្ឌិត និងពិធីប្រគល់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅរាជបណ្ឌិតសភាកម្ពុជា ។ |
| ២៦ | ២៨/០៣/១១ ម៉ោង ១៥:៣០ទី | ប្រជុំពិភាក្សាការងារជាមួយស្ថានទូតកូរ៉េខាងជើង និងឯកឧត្តម **ម៉ម សុផាណា** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៧ | ២៩/០៣/១១ ម៉ោង១៤:៣០នាទី | ដឹកនាំអង្គប្រជុំ ស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២៨ | ៣០/០៣/១១ ម៉ោង ០៨:០០ទី" | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ "ព្រះវិហារ-យ៉ាឡាយ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ |
| ២៩ | ៣១/០៣/១១ ម៉ោង១៤:០០នាទី" | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកការហោះហើរជាថ្មីឡើងវិញ ពីទីក្រុងប៉ារីស មកកាន់រាជធានីភ្នំពេញ របស់ក្រុមហ៊ុនអាកាសចរណ៍អ៊ែរហ្វ្រង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម Thierry MARIANI រដ្ឋលេខាធិការទទួលបន្ទុកផ្នែកដឹកជញ្ជូន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៣០ | ៣១/០៣/១១ ម៉ោង១៩:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងនៃឱកាសប្រារព្ធខួបលើកទី១៥ របស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ អេស ស៊ី អេ និងពិធីសម្ពោធបើកការហោះហើរជាថ្មីឡើងវិញ ពីទីក្រុងប៉ារីស មកកាន់រាជធានីភ្នំពេញ របស់ក្រុមហ៊ុនអាកាសចរណ៍អ៊ែរហ្វ្រង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែល។ |

# សកម្មភាពដ៏ទៃទៀតរបស់ឯកឧត្តម យឹម ណុលសន
# អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៣/១១ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១-សេចក្តីព្រាង ផែនការយុទ្ធសាស្ត្រជាតិ ដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ នៅព្រះរាជាណាចក្រកម្ពុជា ២០១១-២០២៥ ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនពិការ និងគ្រួសារក្រីក្រងាយរងគ្រោះ នៅតាមសហគមន៍ ។<br>៣-បញ្ហាផ្សេងៗ ។ |
| ២ | ១៧/០៣/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវវាង អង្គរក្សរ៉េ ដំហានទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២២/០៣/១១ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីប្រាក់ឧបត្ថម្ភម៉ោងយាមប្រចាំការ ជូនមន្ត្រីរាជការនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។<br>៣-បញ្ហាផ្សេងៗ ។ |
| ៤ | ២៤/០៣/១១ | ប្រជុំពិភាក្សាការងារជាមួយលោក ALAIN BRUN អគ្គនាយកថ្មី នៃអាជ្ញាធរអប្សរា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២៨/០៣/១១ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារវិទ្យាស្ថានខុងជឺ សាលសន្និសីទ របង និងប្រព័ន្ធលូ និងពិធីប្រគល់សញ្ញាបត្រកិត្តិបណ្ឌិត និងពិធីប្រគល់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅរាជបណ្ឌិតសភាកម្ពុជា ។ |
| ៦ | ៣០/០៣/១១ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ "**ព្រះវិហារ-យ៉ាឡាយ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ |
| ៧ | ៣១/០៣/១១ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកការហោះហើរជាថ្មីឡើងវិញ ពីទីក្រុងប៉ារីស មកកាន់រាជធានីភ្នំពេញ របស់ក្រុមហ៊ុនអាកាសចរណ៍អ៊ែរហ្វ្រង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម Thierry MARIANI រដ្ឋលេខាធិការទទួលបន្ទុកផ្នែកដឹកជញ្ជូន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | Ék]tm Km sy sam I L n | អនុប្រធាន គ.ស.វ. |
| និពន្ធនាយក ៖ | Ék]tm gan RN | អគ្គលេខាធិការ គ.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | Ék]tm m sT | សមាជិកបម្រុង គ.ស.វ. |
| និពន្ធអក្ខបទ ៖ | Ék]tm Gg tmR | អគ្គលេខាធិការរង គ.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | Lk sy vs | ប្រធានការិយាល័យ គ.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | Lk bg D3bR | ប្រធានការិយាល័យ គ.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | Lk k Eta | ជំនួយការទេសរដ្ឋមន្ត្រី ប្រធាន គ.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in